## ឯកឧត្តម ចម ប្រសិទ្ធ អញ្ជើញជាអធិបតី ក្នុងពិធីរំលឹកខួបលើកទី៤៣
## ថ្ងៃបង្កើតសមាគមន៍អាស៊ាន នៅសណ្ឋាគារកាំបូឌីយ៉ាណា

ពិធីរំលឹកខួបលើកទី៤៣ ថ្ងៃបង្កើតសមាគមន៍អាស៊ាន រឺហៅថា “**ទិវាអាស៊ាន**” រៀបចំដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបានប្រារព្ធធ្វើឡើង នាល្ងាចថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០១០ ក្រោមអធិបតីភាព ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសម្រាប់កម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ ដោយមានការរៀបចំការពិសារភោជនីអាហារសាមគ្គី និងច្រៀងចំរៀងអាស៊ាន ដោយក្រុមសមាគមនារីអាស៊ាន និងការរាំលេងកំសាន្ត ក្នុងចំណោមភ្ញៀវជាតិ-អន្តរជាតិ ដែលអញ្ជើញចូលរួមជាកិត្តិយស ក្នុងឱកាសនោះផងដែរ ។






មានប្រសាសន៍នាឱកាសនោះ ឯកឧត្តមទេរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក្នុងនាមជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសំរាប់កម្ពុជា បានសំដែងនូវមោទនៈភាព និងបានបញ្ជាក់ថាៈជារៀងរាល់ឆ្នាំនៅថ្ងៃនេះ ប្រទេសជាសមាជិកអាស៊ានទាំង១០ បានប្រារព្ធទិវារបស់ខ្លួន នៅប្រទេសនីមួយៗ នៅលេខាធិការដ្ឋានអាស៊ាន រឺនៅប្រទេសទី៣ ដែលគណៈកម្មការអាស៊ានបានបោះទីតាំងក្រោមទង់ជ័យអាស៊ានបក់រវិច និងការគោរពភ្លេងជាតិអាស៊ានលាន់ឮកងរំពង ។

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ ព្រះរាជាណាចក្រកម្ពុជា បានក្លាយជាសមាជិកទី១០នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថាៈអាស៊ាន ។ ការសម្រេចបាននូវទស្សនៈវិស័យអាស៊ានទាំង១០មិនត្រឹមផ្តល់អត្ថន័យជានិមិត្តរូបប៉ុណ្ណោះទេ ប៉ុន្តែបានធ្វើឱ្យតំបន់អាស៊ីអាគ្នេយ៍ កាន់តែមានកំលាំងខ្លាំងក្លាថែមទៀត ទាំងផ្នែកនយោបាយ និងសេដ្ឋកិច្ច ដែលនៅពេលបច្ចុប្បន្នសំរេចបានផលិតផលសរុបដល់ទៅ១លាន **៥០០ពាន់លានដុល្លាស.រ.អា (១.៥០០.០០០.០០០.០០០) [1.5 Trillion]** ឈរក្នុងលំដាប់លេខ៣ ក្នុងតំបន់អាស៊ី បន្ទាប់ពីជប៉ុននិងចិន។ សំរាប់កម្ពុជាវិញ ការចូលរួមជាសមាជិកអាស៊ានគឺជាការបោះជំហ៊ានមួយយ៉ាងធំ ក្នុងការអនុវត្តគោល នយោបាយ របស់រាជរដ្ឋាភិបាល ដើម្បីធ្វើសមាហរណកម្មប្រទេសយើងនៅក្នុងតំបន់ ព្រមទាំងបង្កើតតួនាទី និងកិត្យានុភាព របស់កម្ពុជា នៅលើពិភពលោក ។ ក្នុងឋានៈជាសមាជិកអាស៊ាន កម្ពុជាបានដើរតួយ៉ាងសកម្ម នៅក្នុងកិច្ចការតំបន់ និង អន្តរជាតិលើគ្រប់វិស័យនយោបាយ សន្តិសុខ សេដ្ឋកិច្ច-ពាណិជ្ជកម្ម សង្គមកិច្ច និងវប្បធម៌ ដើម្បីបុព្វហេតុ សន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់ និងលើពិភពលោកទាំងមូល ។ កម្ពុជា បានខិតខំចូលរួមធ្វើកិច្ចសហប្រតិបត្តិការ ជាមួយប្រទេស សមាជិកអាស៊ានផ្សេងទៀត ដើម្បីសំរេចការប្រែក្លាយសមាគមអាស៊ាន ឱ្យទៅជាសហគមន៍អាស៊ាន ឱ្យបាននៅឆ្នាំ២០១៥ ។

ធម្មនុញ្ញអាស៊ាន ដែលបានចូលជាធរមាន កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាម២០០៨ បានបង្កើតក្រុមប្រឹក្សាសហគមន៍អាស៊ានចំនួន៣ គឺៈក្រុមប្រឹក្សាសហគមន៍នយោបាយ និងសន្តិសុខ-ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ច និងក្រុមប្រឹក្សាសង្គម វប្បធម៌ ដែលកំពុងធ្វើការងារយ៉ាងសកម្មតាមសមត្ថកិច្ចរៀង១ខ្លួន ដើម្បីជំរុញដំណើការសមាហរណកម្មអាស៊ាន និងសំរេចការកសាងសហគមន៍អាស៊ាន សម្រេចឱ្យបាន តាមទិសដៅ នៅឆ្នាំ២០១៥ ។ រហូតមកដល់ពេលនេះ ប្រទេសដែលមិនមែនជាសមាជិកអាស៊ាន ចំនួន៤៤ ប្រទេស បានតែងតាំងឯកអគ្គរដ្ឋទូតប្រចាំនៅលេខាធិការដ្ឋានអាស៊ាន ។ ចំណែក សមាជិកអាស៊ានទាំងអស់ ក៏បានតែងតាំងតំណាងអចិន្ត្រៃយ៍របស់ខ្លួន ប្រចាំនៅលេខាធិការដ្ឋានអាស៊ានផងដែរ ។

ចាប់ពីធម្មនុញ្ញអាស៊ានត្រូវបានចូលជាធរមាន អាស៊ានបានរៀបចំធ្វើកិច្ចប្រជុំជាច្រើន ដើម្បីសំរេចទិសដៅលើគ្រប់វិស័យរបស់អាស៊ាន ដោយអនុលោមទៅតាមមាត្រាទាំងឡាយ នៃធម្មនុញ្ញអាស៊ាន ។ អាទិភាពដ៏សំខាន់របស់អាស៊ាន គឺរៀបចំឱ្យបាននូវផែនការមេ សំរាប់ការតភ្ជាប់រវាងអាស៊ាន និងសំរេចឱ្យបាននូវផែនការមេនេះ ដើម្បីធ្វើសមាហរណកម្មអាស៊ានឱ្យបានពេញលេញលើផ្នែកហេដ្ឋរចនាសម្ព័ន្ធ បច្ចេកវិទ្យាព័ត៌មានគមនាគមន៍ ស្ថាប័ននិងទំនាក់ទំនងរវាងប្រជាជន និងប្រជាជន ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបន្តថាៈ សព្វថ្ងៃនេះអាស៊ានមានតួនាទីស្នូលនៅក្នុងក្របខ័ណ្ឌតំបន់ ដូចជា កិច្ចសន្ទនាអាស៊ាន និងដៃគូចរចារ -វេទិការអាស៊ាន (ASEAN Regional Forum/ARF) -កិច្ចប្រជុំកំពូលអាស៊ីបូព៌ា (East Asia Summit/EASដែលសហព័ន្ធរុស្ស៊ី និងសហរដ្ឋអាមេរិក នឹងចូលរួមនៅពេលខាងមុខនេះ ។ ជាមួយគ្នានេះ អាស៊ាន ក៏មានកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូយុទ្ធសាស្ត្រ ដ៏ល្អជាមួយប្រទេសចិន -ឥណ្ឌា- ជប៉ុន និងសាធារណរដ្ឋកូរ៉េ ហើយក៏មានកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីជាមួយ ប្រទេសទាំងនោះផងដែរ ។

ក្រោយពីកម្ពុជាចូលជាសមាជិកអាស៊ាន កម្ពុជា បានទទួលផលប្រយោជន៍ជាច្រើន ។កម្ពុជាទទួលបានជំនួយពីសមាជិកអាស៊ាន ជាពិសេសខាង អភិវឌ្ឍន៍ធនធានមនុស្ស និង តាមរយៈមូលនិធិសហប្រតិបត្តិការអាស៊ាន-ជប៉ុន អាស៊ាន-ចិន អាស៊ាន-សាធារណរដ្ឋកូរ៉េ ។ល។ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងវិស័យសេដ្ឋកិច្ចសំខាន់ៗដ៏ទៃទៀត។ ម្យ៉ាងវិញទៀត អាស៊ានក៏ជាទីផ្សារមួយដែលមានប្រជាជន សរុបប្រហែល ៦០០លាននាក់ ។ ក្នុងនោះ កម្ពុជាទទួលការអនុគ្រោះពន្ធគយពីប្រទេសសមាជិកអាស៊ានដ៏ទៃទៀត និង ប្រទេសជាដៃគូ ដែលជំរុញឱ្យវិស័យពាណិជ្ជកម្មរបស់កម្ពុជាកាន់តែមានវឌ្ឍនភាព ។

ឯកឧត្តមទេរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបញ្ជាក់បន្ថែមថាៈ នៅឆ្នាំ២០១២ ខាងមុខនេះ កម្ពុជានឹងទទួលធ្វើជាប្រធានអាស៊ាន ដែលនឹងមានកិច្ចប្រជុំជាច្រើន គឺកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ សំខាន់ៗដ៏ទៃទៀត ដូចជាកិច្ចប្រជុំកំពូលអាស៊ាន+១(ជាមួយចិន-ជប៉ុន-កូរ៉េ និងជាមួយឥណ្ឌា) **កិច្ចប្រជុំកំពូលអាស៊ាន+៣** (ជាមួយចិន ជប៉ុន សាធារណរដ្ឋកូរ៉េ) និងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ដែលប្រទេសកម្ពុជាយើងនឹងអាចបំពេញតួនាទីនេះ បានកាន់តែជោគជ័យ ។